ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រួល
ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

# សេចក្តីប្រកាសព័ត៌មាន

នាថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ វេលាម៉ោង ៩:០០ ព្រឹក នៅសាលប្រជុំនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានប្រារព្ធកិច្ចប្រជុំលើកទី ១ របស់គណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (ហៅកាត់ថា **គជសដ**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គជសដ** ។ ចូលរួមក្នុងកិច្ចប្រជុំនេះរួមមាន **ឯ.ឧ. បណ្ឌិត ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា និងជាអនុប្រធានអចិន្ត្រៃយ៍ **គជសដ** ឯកឧត្តម អស់លោក លោកស្រី តំណាងក្រសួងមហាផ្ទៃ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសុខាភិបាល ក្រសួងទេសចរណ៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសភាពាណិជ្ជកម្មកម្ពុជា ដែលជាសមាសភាពនៃ គជសដ ព្រមទាំងមន្ត្រីគយ និងរដ្ឋាករជាសមាសភាពលេខាធិការដ្ឋាននៃ **គជសដ** ជាច្រើនរូបទៀត ។

ថ្លែងនៅក្នុងពិធីបើកកិច្ចប្រជុំនេះ **ឯកឧត្តម គាត ឈន់** ប្រធាន **គជសដ** បានមានប្រសាសន៍អំពីភាពចាំបាច់នៃការបង្កើត **គជសដ** តាមសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ ឯកឧត្តមក៏បានលើកឡើងពីតួនាទី និងភារកិច្ចរបស់ គជសដ ដោយគូសបញ្ជាក់ថាគណៈកម្មាធិការជាតិថ្មីនេះ មានតួនាទីសង្កត់ធ្ងន់តែលើ**ការធ្វើសាមញ្ញកម្មនីតិវិធីគ្រប់គ្រងត្រួតពិនិត្យ និងឃ្លាំមើលការដឹកជញ្ជូនឆ្លងកាត់ព្រំដែននូវទំនិញ** មធ្យោបាយដឹកជញ្ជូននិងពលរដ្ឋប៉ុណ្ណោះ និងមិនសង្កត់ធ្ងន់លើ**ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខ សុវត្ថិភាព និងការងារផ្សេងទៀត** ដែលគណៈកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ ដែលមានស្រាប់កំពុងតែដំណើរការនោះទេ ។ នេះមានន័យថា គណៈកម្មាធិការជាតិទាំងពីរនេះមានភារកិច្ច បំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក និងមិនត្រួតជាន់គ្នាឡើយ ។

បន្ទាប់មក **ឯ.ឧ. បណ្ឌិត ប៉ែន ស៊ីម៉ន** អនុប្រធានអចិន្ត្រៃយ៍ **គជសដ** បានឡើងធ្វើរបាយការណ៍ជូនអង្គប្រជុំអំពីវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន (CBTA) រួមមានរចនាសម្ព័ន្ធការងាររបស់ **គជសដ** ព័ត៌មានសង្ខេបនៃការអនុវត្តកិច្ចព្រមព្រៀងការដឹកជញ្ជូនឆ្លងកាត់ព្រំដែនដោយមានការសម្របសម្រួល រវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងទេសចរណ៍ និងសមាគមភ្នាក់ងារបញ្ជូនទំនិញកម្ពុជា (CAMFFA) ។ ឯកឧត្តមក៏បានចង្អុលបង្ហាញនូវឯកសារគតិយុត្តិជាធរមានមួយចំនួន ដែលពាក់ព័ន្ធនឹងនីតិវិធីគយក្នុងការដឹកជញ្ជូនឆ្លងកាត់ព្រំដែននៃទំនិញ មធ្យោបាយដឹកជញ្ជូន និងមនុស្ស ចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ។ ឯកសារគតិយុត្តិទាំងនេះអាចជាកម្មវត្ថុនៃការស្វែងយល់ ការកែសម្រួល និងការបំពេញបន្ថែមរបស់ **គជសដ** ក្នុងករណីចាំបាច់ តាមបទប្បញ្ញត្តិជាធរមាន និងតាមការអនុវត្តល្អជាអន្តរជាតិ ។

ឯកឧត្តមប្រធាន **គជសដ** បានសម្រេចតាមសំណើរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឲ្យលេខាធិការដ្ឋាន **គជសដ** រៀបចំសិក្ខាសាលាមួយដើម្បីផ្សព្វផ្សាយរាល់បទប្បញ្ញត្តិទាំងអស់ខាងលើ ដើម្បីឲ្យមានការយល់ដឹងដូចគ្នា ក៏ដូចជាផ្តល់ឱកាសដល់គ្រប់ភាគីពាក់ព័ន្ធដើម្បីលើកឡើងនូវបទប្បញ្ញត្តិរបស់ខ្លួនពាក់ព័ន្ធការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ប្រសិនបើមាន ។ បន្ទាប់មកឯកឧត្តមក៏បានលើកឡើងនូវគំនិតផ្តួចផ្តើមលើការបង្កើតអនុគណៈកម្មាធិការចំនួនពីរ អម **គជសដ** គឺអនុគណៈកម្មាធិការប្រតិបត្តិ និងអនុគណៈកម្មាធិការអនុលោមភាព ដើម្បីធានានូវប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ **គជសដ** ដោយទុកលទ្ធភាពឲ្យសមាជិកអង្គប្រជុំលើកយកទៅពិភាក្សាផ្ទៃក្នុងអង្គភាពរបស់ខ្លួន មុននឹងពិនិត្យសម្រេច នៅក្នុងអង្គប្រជុំលើកក្រោយ ។

ជាកិច្ចបញ្ចប់ **ឯកឧត្តម គាត ឈន់** ប្រធាន គជសដ បានថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំ និងបានជូនពរឲ្យបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងនាមជាសមាសភាពនៃ គជសដ បានជោគជ័យ និងមានប្រសិទ្ធភាព ដើម្បីឈានទៅសម្រេចឲ្យបាននូវគោលនយោបាយជម្រុញកំណើនសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

កិច្ចប្រជុំលើកទី ១ របស់គណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែននេះ បានបញ្ចប់នាម៉ោង ១១:៣០ ព្រឹក ថ្ងៃដដែល ក្រោមបរិយាកាសការងារ រីករាយ និងស្និទ្ធស្នាល ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០

# Press Release

In Phnom Penh, Cambodia on October 25, 2010 9:00AM, the first meeting on National Cross-Border Transport Facilitation Committee - NCTFC has been held at the Meeting Hall of GDCE and presided over by **H.E. Keat Chhon**, Deputy Prime Minister, Minister of Economy and Finance, and the Head of NCTFC. It was attended by **H.E Dr. Pen Siman**, Delegate of the Royal Government of Cambodia, Director General of Customs and Excise and the permanent Deputy Head of NCTFC, the member of NCTFC who are representatives from Ministry of Interior, Ministry of International Affairs and International Cooperation, Ministry of Commerce, Ministry of Agriculture, Forest and Fishery, Ministry of Public Work and Transport, Ministry of Health, Ministry of Tourism, the Council for the Development of Cambodia, and other customs officers who are member of the NCTFC's secretariat.

**H.E Keat Chhon**, Head of NCTFC, raised the necessarily requirement to establish the NCTFC in accordant with the high decision of Samdech Akka Moha Sena Padei Techo **Hun Sen**, Prime Minister of the Kingdom of Cambodia . He also mentioned about the obligations and responsibilities of NCTFC by clarifying that, the important obligation of this new national committee is to simplify the procedure of management control and observing the Cross-Border Transport goods, means of transport, and human only, but it was not developing structure, security, safety, and others which are the jobs of National Transport Coordinating Committee, the existing and currently operational committee. It means that the both committees have to work complementarily for each other.

Then **H.E. Dr. Pen Siman**, Permanent Deputy Head of NCTFC, reported on the progress report of the implementation of Cross-Border Transport Agreement - CBTA, which was including administration organization chart of NCTFC, brief on the operational of CBTA which was coordinated by the General department of Customs and Excise of Cambodia, Ministry of Public Work and Transportation, and Cambodia Freight Forwarders Association - CAMFFA. He also indicated many regulations related customs regulation for customs transit crossing border on goods, means of transport, human, import-export via the Kingdom of Cambodia. Those regulations may subject to understanding, revise

and complementary of NCTFC as desired in accordant with the laws and for the good international implementation.

H.E. head of NCTFC approved on the request of the GDCE on a seminar on the presentation of above regulations which will be launched by secretariat of NCTFC for the same understanding and giving the opportunity to related members to raise on their own regulations which relegated to cross-border transportation. And then H.E. also raised about basic concept to establish two sub-committee follow the NCTFC are **Operational sub-committee** and **Complaint sub-committee** in order to guarantee the NCTFC operational's effectiveness by giving chance to participants for internal discussion before verifying and approval on further meeting.

Finally **H.E. Keat Chhon**, Head of NCTFC, thanks to all participants and wishing them to get successful and effective job as the member NCTFC in order to achieve the national economy development goal, reducing poor, of the Royal Government of Cambodia under the leadership of Samdech Akka Moha Sena Padei Techo **Hun Sen**, Prime Minister of the Kingdom of Cambodia.

The first meeting of National Cross-Border Transport Facilitation Committee finished on 11:30AM on the same day with workable happy and friendly's atmosphere.

25 October, 2010